គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ

គ.ប.ផ.ក.

COUNTER COUNTERFEIT COMMITTEE OF CAMBODIA

C.C.C.C

ការអនុវត្តនីតិវិធីរបស់ គ.ប.ផ.ក.

ចំពោះបទល្មើសកម្មសិទ្ធិបញ្ញាពាក់ព័ន្ធ

នឹងការនាំចូល ផលិត រក្សាទុក

លក់ ចែកចាយ ផលិតផលក្លែងក្លាយ

មាតិកា

I. អំពី គ.ប.ផ.ក.

II. បទល្មើសកម្មសិទ្ធិបញ្ញា

III. ការដាក់ពាក្យបណ្តឹងមក គ.ប.ផ.ក.

IV. ចំណាត់ការនីតិវិធីរបស់ គ.ប.ផ.ក.

I. អំពី គ.ប.ផ.ក.



ក. ប្រវត្តិ គ.ប.ផ.ក.

ខ. រចនាសម្ព័ន្ធ គ.ប.ផ.ក.

គ. តួនាទីការកិច្ច គ.ប.ផ.ក.

I. អំពី គ.ប.ផ.ក.

ក. ប្រវត្តិគណៈកម្មាធិការ

- គ.ប.ផ.ក គឺជាគណៈកម្មាធិការថ្នាក់ជាតិ ដែលត្រូវបានផ្តួចផ្តើមបង្កើតឡើងដោយ **សម្តេចក្រឡាហោម** ស ខេង **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ១៥០ សសរ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤។
- សមាសភាពអន្តរក្រសួងរបស់ គ.ប.ផ.ក រួមមានតំណាងមកពីក្រសួង-ស្ថាប័នចំនួន ២៤៖

១. ក្រសួងមហាផ្ទៃ
២. ក្រសួងការពារជាតិ
៣. ក្រសួងយុត្តិធម៌
៤. ក្រសួងសុខាភិបាល
៥. ក្រសួងឧស្សាហកម្ម និង សិប្បកម្ម
៦. ក្រសួងព័ត៌មាន
៧. ក្រសួងទេសចរណ៍
៨ ក្រសួងអប់រំ យុវជន និងកីឬ
៩. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
១០. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
១១. ក្រសួងពាណិជ្ជកម្ម...។ល។

ពិធី
ប្រកាសសមាសភាព គណៈកម្មាធិការប្រយុទ្ធប្រឆាំង
ជំងឺតាមផ្លូវភ្លើយ ដែលបង្ក្រោះថ្នាក់មានមានិតិយខ្ពស់
ដល់សុខភាព និងសុវត្ថិភាពសង្គម
ក្រសួងមហាផ្ទៃ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៤

២. រចនាសម្ព័ន្ធ គ.ប.ផ.ក.

២. រចនាសម្ព័ន្ធ គណៈកម្មាធិការ



គ. តួនាទីការកិច្ច គ.ប.ផ.ក.

គ.ប.ផ.ក មានដែនសមត្ថកិច្ចទូទាំងព្រះរាជាណាចក្រកម្ពុជា និងមានការកិច្ចដូចតទៅ៖

- សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ
- ស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសពាក់ព័ន្ធនឹងការនាំចូល ការផលិត ការស្តុកទុក និងការចែកចាយផលិតផលក្លែងក្លាយ និងខុសច្បាប់
- អប់រំ ផ្សព្វផ្សាយដល់សាធារណៈជន អំពីផលប៉ះពាល់ នៃផលិតផលក្លែងក្លាយ។
- បង្កើតភាពជាដៃគូរជាមួយមន្ត្រីអនុវត្តច្បាប់នៃស្ថាប័នពាក់ព័ន្ធ ព្រមទាំងវិស័យឯកជនពាក់ព័ន្ធនឹងការទប់ស្កាត់ផលិតផលក្លែងក្លាយនៅកម្ពុជា ក្នុងតំបន់ និងជាអន្តរជាតិ។
- រាយការណ៍ជាប្រចាំ ពីការអនុវត្តការងាររបស់ខ្លួន ព្រមទាំងសមិទ្ធផលជូន សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

សកម្មភាព

សិក្ខាសាលាបណ្តុះបណ្តាល

មន្ត្រីអនុវត្តច្បាប់ និងរបៀបកត់សម្គាល់

ផលិតផលពិត និងក្លែងក្លាយ



សកម្មភាព

វេទិការស្តីពីកម្មសិទ្ធិបញ្ញា (IPR FORUM 2018)

សកម្មភាព

សន្និសីទថ្នាក់តំបន់ ស្តីពីឱសថក្លែងក្លាយ និងអន់គុណភាព នៅភ្នំពេញ (២០១៩)

សកម្មភាព

ពិធីចុះហត្ថលេខាអនុស្សរណៈ
នៃការយោគយល់គ្នារវាង គ.ប.ផ.ក
និង EUROCHAM នៅកម្ពុជា



សកម្មភាព

ចុះត្រួតពិនិត្យ និងបង្ក្រាបផលិតផលក្លែងក្លាយ ខុសច្បាប់

សកម្មភាព

សន្និសីទសារព័ត៌មាន ស្តីពីលទ្ធផលចុះបង្ក្រាប

សកម្មភាព និងលទ្ធផល

ការកំទេចផលិតផលចំណីអាហារខូចគុណភាព និងខុសច្បាប់ចំនួនប្រមាណជាង ១00តោន

សកម្មភាព និងលទ្ធផល

ការកំទេចផលិតផលគ្រឿងសម្អាងក្លែងក្លាយ និងខុសច្បាប់ចំនួន ៨១ គោន

II. បទល្មើសកម្មសិទ្ធិបញ្ញា

ក. អ្វីទៅជាកម្មសិទ្ធិបញ្ញា (Intellectual Property)?

- ស្នាដៃដែលបង្កើតឡើងដោយគំនិត ឬបញ្ញាញ្ញាណរបស់មនុស្ស។
- កម្មសិទ្ធិបញ្ញាមានពីរប្រភេទគឺ៖

១. កម្មសិទ្ធិឧស្សាហកម្ម៖ ប៉ាតង់, គំនូរឧស្សាហកម្ម, ពាណិជ្ជនាម, ម៉ាក, ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ...។ល។)

២. សិទ្ធិអ្នកនិពន្ធ៖ ចម្រៀង, កំណាព្យ, ភាពយន្ត, ប្រលោមលោក, គំនូរ, ចម្លាក់...។ល។

- កម្មសិទ្ធិបញ្ញាទទួលបានការការពារ ដរាបណាបានចុះបញ្ជីជាមួយស្ថាប័នមានសមត្ថកិច្ច។ នៅកម្ពុជាការចុះបញ្ជី កម្មសិទ្ធិឧស្សាហកម្មជាសមត្ថកិច្ចរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ហើយការចុះបញ្ជីសិទ្ធិអ្នក និពន្ធជាសមត្ថកិច្ចរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

II. បទល្មើសកម្មសិទ្ធិបញ្ញា

ខ. អ្វីទៅជាផលិតផលក្លែងក្លាយ?

ផលិតផលក្លែងក្លាយគឺជាទង្វើមួយនៃការរំលោភកម្មសិទ្ធិបញ្ញា និងជាបែបផែនមួយនៃការប្រកួតប្រជែងមិនស្មោះត្រង់។

- <u>និយមន័យតាមច្បាប់អន្តរជាតិ</u>

“ ទំនិញពាក់ម៉ាកក្លែងក្លាយមានន័យថា ទំនិញណាមួយ រួមទាំងការវេចខ្ចប់ផង ដែលពាក់ម៉ាកដោយគ្មានការ អនុញ្ញាត ដែលដូចទៅនឹងម៉ាកដែលបានចុះបញ្ជីស្របច្បាប់ចំពោះទំនិញនេះ ឬដែលមិនអាចញ្ញែកដាច់ពីគ្នាបាននូវផ្នែកសំខាន់នៃម៉ាកនេះ ហើយដែលរំលោភបំពានសិទ្ធិម្ចាស់ម៉ាកនោះតាមច្បាប់នៃប្រទេសនាំចូល។”

(មាត្រា ៥១ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញាឆ្នាំ១៩៩៤)

II. បទល្មើសកម្មសិទ្ធិបញ្ញា

II. បទល្មើសកម្មសិទ្ធិបញ្ញា



LEVI'S® PACKAGING
Genuine vs. Counterfeit Examples

GENUINE | **COUNTERFEIT**

LEVI'S® SUNDRIES
Buttons, Patches, Zippers, Tabs, etc.

Waistband Patch
- Usually tan or black, but colors can vary with certain product lines and per season.
- The patch should be sewn evenly along the line which borders the design.
- On most Levi's® jeans, the thread color of the stitching should match or closely match the patch color.

4

II. បទល្មើសកម្មសិទ្ធិបញ្ញា

- <u>និយមន័យតាមច្បាប់ជាតិ</u>

“ ទំនិញដែលពាក់ម៉ាកក្លែងក្លាយមានន័យថា ទំនិញទាំងឡាយរួមទាំងសំបកវេចខ្ចប់ផង ដែលមានម៉ាកដូចគ្នាទៅនឹងម៉ាកដែលបានចុះបញ្ជីត្រឹមត្រូវទាក់ទងទៅនឹងទំនិញនោះ ដោយគ្មានការអនុញ្ញាត ឬមិនអាចសម្គាល់បាននូវលក្ខណៈខុសគ្នា ពីទិដ្ឋភាពសំខាន់ៗនៃម៉ាក និងដែលរំលោភបំពានសិទ្ធិរបស់ម្ចាស់ម៉ាកស្របច្បាប់ ក្រោមច្បាប់នៃប្រទេសនាំចូល។”

(មាត្រា ៦១ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់)

II. បទល្មើសកម្មសិទ្ធិបញ្ញា

- <u>និយមន័យកំណត់ដោយច្បាប់ពិសេសមួយចំនួន</u>

ច្បាប់ស្តីពីការគ្រប់គ្រងគុណភាពទំនិញ និងសេវាកម្ម (២១ មិថុនា ២០០០)

- ទោះជាភាគីចុះកិច្ចសន្យាក្តី មិនមែនភាគីចុះកិច្ចសន្យាក្តី ឬតាមរយៈតតិយជនក្តី ត្រូវហាមឃាត់ការក្លែងបន្លំ ឬការប៉ុនប៉ងក្លែងបន្លំតាមមធ្យោបាយ ឬវិធីណាក៏ដោយលើផលិតផលទំនិញ និងសេវាចំពោះ៖

- អត្តសញ្ញាណ យថាប្រភេទ ប្រភេទ ប្រភព គុណភាពខាងរូបធាតុ ឬខាងទ្រង់ទ្រាយរាងកាយ ធាតុផ្សំ បរិមាណ
- កិច្ចត្រួតពិនិត្យដែលបានធ្វើ វិធីប្រើ សម្បទារចំពោះការប្រើប្រាស់ គ្រោះថ្នាក់ភ្ជាប់នឹងការប្រើប្រាស់ ការប្រុងប្រយ័ត្នដែលត្រូវប្រកាន់យកនៃគ្រប់ផលិតផលទំនិញ ឬសេវា
- វិធីនិងកាលបរិច្ឆេទនៃការផលិត និងការប្រើប្រាស់ ឬនៃការបរិភោគបណ្តាផលិតផលទំនិញ។ (មាត្រា ១៦)

II. បទល្មើសកម្មសិទ្ធិបញ្ញា

<u>ច្បាប់ស្តីពីការគ្រប់គ្រងគុណភាពទំនិញ និងសេវាកម្ម (២១ មិថុនា ២០០០)</u>

- ត្រូវបានហាមឃាត់ដាច់ខាតការក្លែងផលិតផលទំនិញដែលជាកម្មវត្ថុធ្វើពាណិជ្ជកម្ម ឬទុកសម្រាប់ធ្វើពាណិជ្ជកម្ម ដោយធ្វើការកែច្នៃផលិតផលទំនិញតាមរបៀបណាមួយ ដោយធ្វើការបញ្ចូលបន្ថែម ការដកចេញ ឬការប្តូរជំនួស នៃភាគណាមួយ ឬភាគទាំងមូលដែលពុំត្រូវបានអនុញ្ញាតឲ្យធ្វើដោយបទបញ្ញត្តិ ឬដោយទម្លាប់ បើពុំមានបទបញ្ញត្តិ ឬដែលមិនសមស្របទៅនឹងបទបញ្ញត្តិ។ (មាត្រា ១៧)

II. បទល្មើសកម្មសិទ្ធិបញ្ញា

ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

➢ ការក្លែងម៉ាក

ម្ចាស់ដើមនៃម៉ាកមានសិទ្ធិប្តឹងទៅតុលាការប្រឆាំងនឹងជនណាម្នាក់ដែលប្រើប្រាស់ដោយរំលោភនូវម៉ាករបស់ខ្លួន ដោយគ្មានការយល់ព្រមពីម្ចាស់ដើម។ ម្ចាស់ដើមក៏មានសិទ្ធិប្តឹងផងដែរ ចំពោះការប្រើប្រាស់នូវសញ្ញាដែលប្រហាក់ប្រហែលនឹងម៉ាក ដែលខ្លួនបានចុះបញ្ជីរួចហើយ និងការប្រើប្រាស់ម៉ាកដែលទាក់ទិនទៅនឹងទំនិញ និងសេវាដែលប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវានៃម៉ាកដែលចុះបញ្ជីរួចហើយនោះ ហើយដែលអាចបណ្តាលឲ្យមានការភាន់ច្រលំជាសាធារណៈ។ (មាត្រា ១១.ខ)

II. បទល្មើសកម្មសិទ្ធិបញ្ញា

ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

➢ អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

ទង្វើទាំងឡាយដូចខាងក្រោមត្រូវចាត់ទុកថាបានបង្កើតនូវអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់៖

ក. ការបង្កើតឲ្យមានការភ័ន្តច្រលំតាមមធ្យោបាយណាមួយ ជាមួយសហគ្រាស ជាមួយទំនិញ ឬជាមួយសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង... (មាត្រា ២៣)

II. បទល្មើសកម្មសិទ្ធិបញ្ញា

ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ (២ វិច្ឆិកា ២០១៩)

- អំពើមិនសុចរិតទាក់ទងនឹងទំនិញ

បុគ្គលទាំងឡាយដែលធ្វើធុរកិច្ចមិនត្រូវពាក់ព័ន្ធនឹងអំពើមិនសុចរិតដែលមានលក្ខណៈជាការបំភាន់ ឬបោកបញ្ឆោតដល់សាធារណជន ទាក់ទងនឹងប្រភេទ ដំណើរការផលិត ចរិតលក្ខណៈ ភាពសមតាមបំណង បរិមាណ រង្វាស់រង្វាល់ ក្រិតខ្នាត ស្តង់ដារ ឬគុណភាពនៃទំនិញឡើយ។ (មាត្រា ១០)

- អំពើមិនសុចរិតទាក់ទងនឹងសេវា

បុគ្គលទាំងឡាយដែលធ្វើធុរកិច្ចមិនត្រូវពាក់ព័ន្ធនឹងអំពើមិនសុចរិតដែលមានលក្ខណៈជាបំភាន់ ឬបោកបញ្ឆោតដល់សាធារណជន ទាក់ទងនឹងប្រភេទ ស្តង់ដារ ចរិតលក្ខណៈ ភាពសមតាមបំណង ទំហំ ឬគុណភាពនៃសេវាឡើយ។

(មាត្រា ១១)

II. បទល្មើសកម្មសិទ្ធិបញ្ញា

<u>ច្បាប់ស្តីពីការគ្រប់គ្រងឱសថ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ</u>

➢ ឱសថក្លែងក្លាយ

- ឱសថក្លែងក្លាយសម្តៅដល់ប្រភេទឱសថដែលគ្មានសារជាតិសកម្ម ឬមានសារជាតិសកម្មមិនត្រឹមត្រូវតាមរូបមន្ត ដែលកំណត់លើផ្លាកសញ្ញា ឬមានសារជាតិសកម្មមិនគ្រប់ចំនួនតាមកម្រិតកំណត់លើផ្លាកសញ្ញា ឬមានការវេចខ្ចប់ របៀបបង្ហាញរចនាបថ អត្តសញ្ញាណស្រដៀង ឬដូចគ្នានឹងឱសថមួយផ្សេងទៀតដែលជាឱសថពិត ឬផលិត ឬវេចខ្ចប់ដោយគ្មានអាជ្ញាប័ណ្ណពីក្រសួងសុខាភិបាល។

(មាត្រា ២ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ)

II. បទល្មើសកម្មសិទ្ធិបញ្ញា

<u>អនុក្រឹត្យលេខ ១២២ អនក្រ.បក ស្តីពីការគ្រប់គ្រងគ្រឿងសម្អាង (២៨ សីហា ២០០៨)</u>

- គ្រឿងសម្អាងក្លែងក្លាយ

គ្រឿងសម្អាងក្លែងក្លាយ ឬក្លែងបន្លំសម្គាល់លើផលិតផល៖

- ដែលមានសារធាតុផ្សំមិនគ្រប់ចំនួន ខុសកម្រិត ឬមិនត្រឹមត្រូវតាមសមាសធាតុផ្សំដែលផលិតករបានរៀបរាប់ក្នុងឯកសារទុកនៅក្រុមហ៊ុន ឬរូបមន្តដែលបានកំណត់នៅលើស្លាកសញ្ញាផលិតផល។
- ដែលផលិត ឬវេចខ្ចប់ ដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលគ្មានអាជ្ញាប័ណ្ណពីស្ថាប័នមានសមត្ថកិច្ច។
- ដែលមានស្លាកសញ្ញា ឬមានការវេចខ្ចប់ របៀបបង្ហាញរចនាបថ អត្តសញ្ញាណស្រដៀងនឹងគ្រឿងសម្អាងមួយផ្សេងទៀត ដែលជាគ្រឿងសម្អាងពិត។(មាត្រា ៣)

III. ការដាក់ពាក្យបណ្តឹងមក គ.ប.ផ.ក.

ក. ជនដែលអាចដាក់ពាក្យបណ្តឹងមក គ.ប.ផ.ក

ខ. នីតិវិធីនៃការដាក់ពាក្យបណ្តឹង និងឯកសារភ្ជាប់

III. ការដាក់ពាក្យបណ្តឹងមក គ.ប.ផ.ក.

ក. ជនដែលអាចដាក់ពាក្យបណ្តឹងមក គ.ប.ផ.ក.

១. សាធារណជន

បុគ្គលគ្រប់រូបដែលទទួលបានព័ត៌មានអំពីបទល្មើសពាក់ព័ន្ធនឹងផលិតផលក្លែងក្លាយ អាចដាក់ពាក្យបណ្តឹងមក គ.ប.ផ.ក. ។

២. ជនរងគ្រោះនៃផលិតផលក្លែងក្លាយ

រាល់បុគ្គលទាំងឡាយដែលជាជនរងគ្រោះនៃការជាវ ឬការប្រើប្រាស់ទំនិញ ឬសេវាកម្មក្លែងក្លាយ អាចដាក់ពាក្យបណ្តឹងមក គ.ប.ផ.ក.។

៣. ម្ចាស់ម៉ាក ឬផលិតផល

រាល់បុគ្គលទាំងឡាយ ទាំងរូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាម្ចាស់ម៉ាកលើទំនិញ ឬសេវាកម្មដែលបានចុះបញ្ជីត្រឹមត្រូវនៅកម្ពុជា ឬទទួលបានការការពារជាអន្តរជាតិ អាចដាក់ពាក្យបណ្តឹងមក គ.ប.ផ.ក. បាន ក្នុងករណីមានការក្លែងម៉ាកសញ្ញាផលិតផលជាទំនិញ ឬសេវាកម្មរបស់ខ្លួន។

III. ការដាក់ពាក្យបណ្តឹងមក គ.ប.ផ.ក.

ខ. នីតិវិធីនៃការដាក់ពាក្យបណ្តឹង និងឯកសារយោង៖

អ្នកដាក់ពាក្យបណ្តឹងអាចដាក់ពាក្យបណ្តឹងមកការិយាល័យទទួលសំណុំរឿងនៃលេខាធិការដ្ឋានរបស់ គ.ប.ផ.ក. ដែលមានទីតាំងនៅក្នុងក្រសួងមហាផ្ទៃ អាគារ H ដោយភ្ជាប់ជាមួយពាក្យបណ្តឹងនូវព័ត៌មានដូចខាងក្រោម៖

- អត្តសញ្ញាណម្ចាស់បណ្តឹង (ឯកសារចុះបញ្ជី ក្នុងករណីម្ចាស់បណ្តឹងជានីតិបុគ្គល)។
- លិខិតប្រគល់សិទ្ធិតំណាងឲ្យដាក់ពាក្យបណ្តឹង (ក្នុងករណីដែលម្ចាស់ម៉ាកប្រគល់សិទ្ធិដល់តតិយជនឲ្យប្តឹងជំនួស)។
- វិញ្ញាបនបត្រចុះបញ្ជីផលិតផលដើមនៅប្រទេសសាមី ឬនៅកម្ពុជា និងគម្រូផលិតផលដើម។
- ព័ត៌មានបទល្មើស និងជនល្មើស (ប្រសិនជាមាន) និងគម្រូផលិតផលក្លែងក្លាយ។
- លទ្ធផលនៃការធ្វើវិភាគ និងការចង្អុលបង្ហាញភាពខុសគ្នារវាងផលិតផលពិត និងផលិតផលក្លែងក្លាយ។

IV. ចំណាត់ការនីតិវិធីរបស់ គ.ប.ផ.ក.

ក. ការកសាងកំណត់ហេតុលើពាក្យបណ្តឹង៖

- បន្ទាប់ពីទទួលបានពាក្យបណ្តឹង គ.ប.ផ.ក. ធ្វើការកោះហៅម្ចាស់បណ្តឹងឲ្យចូលមកលេខាធិការដ្ឋាន របស់ គ.ប.ផ.ក. ដើម្បីផ្តល់នូវសេចក្តីរាយការណ៍លើពាក្យបណ្តឹងរបស់ខ្លួនទៅក្នុងកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹង ។
- បន្ទាប់ពីពិនិត្យមើលមូលដ្ឋានភ័ស្តុតាងដែលប្តល់ដោយម្ចាស់បណ្តឹង ឬបានមកពីលទ្ធផលនៃការស៊ើបអង្កេត និងបន្ទាប់ពីបានពិនិត្យអត្ថិភាពនៃបទល្មើស គ.ប.ផ.ក.បញ្ជូនពាក្យបណ្តឹង រួមទាំងកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងទៅព្រះរាជអាជ្ញា ព្រមទាំងស្នើសុំការចុះបង្ក្រាប។

IV. ចំណាត់ការនីតិវិធីរបស់ គ.ប.ផ.ក.

ខ. ការស៊ើបអង្កេតដោយ គ.ប.ផ.ក.

- ក្នុងករណីដែលភ័ស្តុតាងមិនគ្រប់គ្រាន់ ហើយបទល្មើសជាបទល្មើសមិនជាក់ស្តែង គ.ប.ផ.ក. អាចបើកការស៊ើបអង្កេតបឋមបាន។
- ការស៊ើបអង្កេតអាចធ្វើនៅទីតាំងស្តុករក្សាទុក និងចែកចាយផលិតផលក្លែងក្លាយ ឬ សហគ្រាសផ្គត់ផ្គង់វត្ថុធាតុដើម
- គ.ប.ផ.ក. អាចស្នើសុំម្ចាស់បណ្តឹងអោយសហការ និងផ្តល់តម្រុយដែលពាក់ព័ន្ធនឹងបទល្មើសដូចជាព័ត៌មានដែលពាក់ព័ន្ធនឹងជនល្មើស ទីតាំងបទល្មើស អត្តសញ្ញាណផលិតផលក្លែងក្លាយ ប្រភពនាំចូល និងគោលដៅនៃការចែកចាយ...។ល។
- ក្នុងករណីមួយចំនួន ក៏មានការស្នើសុំពីសំណាក់រដ្ឋដទៃ ឲ្យ គ.ប.ផ.ក. សហការស៊ើបអង្កេតលើផលិតផលក្លែងក្លាយ និងបង្ក្រាប។

IV. ចំណាត់ការនីតិវិធីរបស់ គ.ប.ផ.ក.

គ. ការចុះបង្ក្រាបរបស់ គ.ប.ផ.ក.

- ចូលទៅទីតាំងនាំចូល រក្សាទុក និងលក់ចែកចែកផលិតផលក្លែងក្លាយ ដោយប្រកាសសមាសភាពកងកម្លាំងបង្ក្រាប និងបង្ហាញលិខិតបញ្ជារបេសកកម្ម ឬដីកាបញ្ជារបស់មន្ត្រីតុលាការ ដល់ម្ចាស់ទីតាំង។
- ប្រកាសអំពីគោលបំណងនៃការចុះបង្ក្រាបទីតាំង ដល់ម្ចាស់ ឬអ្នកទទួលខុសត្រូវលើទីតាំង។
- ស្នើសុំឆែកឆេរទីតាំង និងស្នើសុំអោយម្ចាស់ទីតាំងសហការជាមួយមន្ត្រី គ.ប.ផ.ក.។
- ធ្វើការសួរយកចម្លើយម្ចាស់ទីតាំង និងជនសង្ស័យផ្សេងទៀតដែលមានវត្តមាននៅទីតាំងនាំចូល រក្សាទុក និងចែកចាយផលិតផលក្លែងក្លាយ។
- មន្ត្រីជំនាញ គ.ប.ផ.ក. ចូលទៅគ្រប់គ្រងវត្ថុតាងនៅលើទីតាំង ជៀសវាងការបំផ្លាញចោល ការចល័តចេញពីទីតាំង ឬការលាក់បំបាំងវត្ថុតាង។

សកម្មភាពចុះបង្ក្រាបរបស់ គ.ប.ផ.ក.

ការចុះបង្ក្រាបផលិតផលគ្រឿងសម្អាងក្លែងក្លាយ និងខុសច្បាប់

ការចុះបង្ក្រាបផលិតផលក្លែងក្លាយ



ការចុះបង្ក្រាបផលិតផលក្លែងក្លាយ

ចុះត្រួតពិនិត្យ និងបង្ក្រាបផលិតផលក្លែងក្លាយ ខុសច្បាប់

ការចុះបង្ក្រាបផលិតផលក្លែងក្លាយ

ចុះត្រួតពិនិត្យ និងបង្ក្រាបផលិតផលក្លែងក្លាយ ខុសច្បាប់

ការចុះបង្ក្រាបផលិតផលក្លែងក្លាយ

ចុះត្រួតពិនិត្យ និងបង្ក្រាបចំណីអាហារអន់គុណភាព និងខុសច្បាប់

IV. ចំណាត់ការនីតិវិធីរបស់ គ.ប.ផ.ក.

➢ ការធ្វើតេស្តលើសំណាក

- គ.ប.ផ.ក. ប្រើប្រាស់ការធ្វើតេស្តបឋមនៅទីតាំងបទល្មើស ដោយប្រើប្រាស់មន្ទីរពិសោធន៍ចល័ត ឬបញ្ជូនទៅធ្វើតេស្តនៅ មន្ទីរពិសោធន៍ផលិតផលក្លែងក្លាយ របស់ គ.ប.ផ.ក. ឬមន្ទីរពិសោធន៍ជំនាញថ្នាក់ជាតិ។
- គ.ប.ផ.ក. អាចទំនាក់ទំនងជាមួយម្ចាស់ម៉ាក ឬម្ចាស់ផលិតផលដើម ដើម្បីបញ្ជូនសំណាកទៅធ្វើតេស្តនៅ មន្ទីរពិសោធន៍ជំនាញរបស់ម្ចាស់ផលិតផលដើម ឬមន្ទីរពិសោធន៍អន្តរជាតិដែលជាដៃគូរសហការរបស់ គ.ប.ផ.ក.។



IV. ចំណាត់ការនីតិវិធីរបស់ គ.ប.ផ.ក.

➢ ការដកហូតសំណាក

- គ.ប.ផ.ក.ធ្វើការដកហូតសំណាកយ៉ាងហោចណាស់ចំនួន ០៣ ឯកត្តា មករក្សាទុក ដោយ រក្សាទុក ០១ នៅអង្គភាព,០១ បញ្ជូនទៅធ្វើកោសល្យវិច្ច័យ និង០១ទៀតសម្រាប់បញ្ជូនទៅតុលាការ។
- ត្រូវកសាងកំណត់ហេតុមន្ត្រីនគរបាលយុត្តិធម៌ពាក់ព័ន្ធនឹងប្រតិបត្តិការចុះបង្ក្រាបបទល្មើស ដោយមានការចុះហត្ថលេខាពីម្ចាស់ទីតាំង និងមន្ត្រីមានសមត្ថកិច្ចដែលចូលរួមការបង្ក្រាប (កម្លាំងចម្រុះ, អាជ្ញាធរដែនដី...។ល។)

➢ ការរឹបអូសវត្ថុតាងដែលមានគ្រោះថ្នាក់

- គ.ប.ផ.ក. ស្នើសុំតុលាការដើម្បីរឹបអូសវត្ថុតាងដែលមានគ្រោះថ្នាក់ដល់អាយុជីវិត និងសុខភាពរបស់មនុស្ស ដើម្បីកម្ទេចចោលនៅរៀងរាល់ដំណាច់ឆមាស ឬរៀងរាល់មួយឆ្នាំម្តង។
- គ.ប.ផ.ក. នឹងធ្វើការប្រគល់វត្ថុតាងដែលពុំមែនជាផលិតផលក្លែងក្លាយជូនម្ចាស់ដើមវិញ បន្ទាប់ពីមានការឯកភាពពីព្រះរាជអាជ្ញា។

IV. ចំណាត់ការនីតិវិធីរបស់ គ.ប.ផ.ក.

➢ ការថែរក្សាទុកវត្ថុតាង

- គ.ប.ផ.ក. អាចដឹកជញ្ជូនវត្ថុតាងមកការក្សាទុកនៅអង្គភាព ឬផ្ទើទុកនៅទីតាំងបទល្មើសបន្ទាប់ពីមានការអនុញ្ញាតពី ព្រះរាជអាជ្ញាឲ្យធ្វើការបិតទីតាំងបណ្តោះអាសន្ន។
- វត្ថុតាងនីមួយៗមានបញ្ជាក់អំពីប្រភេទ និងចំនួនច្បាស់លាស់ ដោយមានការទទួលស្គាល់ពីម្ចាស់ទីតាំង។
- ចំពោះវត្ថុតាងដែលអាចផ្តល់តម្រុយដល់ការស៊ើបអង្កេតបន្ត ត្រូវបានបញ្ជូនទៅធ្វើការវិភាគ ឬកោសល្យវិច្ច័យនៅមន្ទីរពិសោធន៍ផលិតផលក្លែងក្លាយរបស់ គ.ប.ផ.ក.។
- គ.ប.ផ.ក. ពិភាក្សាជាមួយអ្នកជំនាញ ក្នុងករណីវត្ថុតាងមួយចំនួនដែលអាចបង្កគ្រោះថ្នាក់ដល់មនុស្ស។

IV. ចំណាត់ការនីតិវិធីរបស់ គ.ប.ផ.ក.

ង. ការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា

- **គ.ប.ផ.ក** មានសិទ្ធិធ្វើការឃាត់ខ្លួនជនសង្ស័យរួមទាំងវត្ថុតាងក្នុងរយៈពេល ៤៨ ម៉ោង ប្រសិនណាជាបទល្មើសនោះពាក់ព័ន្ធនឹងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់ និងមានហានិភ័យខ្ពស់ដល់អាយុជីវិត និងសុខភាពរបស់មនុស្ស។ ថិរវេលានេះត្រូវចាប់ផ្តើមគិតពីពេលដែលជនសង្ស័យមកដល់លេខាធិការដ្ឋានរបស់ គ.ប.ផ.ក.។

- គ.ប.ផ.ក. ធ្វើការរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា អំពីការឃាត់ខ្លួននេះ។

- នៅពេលផុតកំណត់រយៈពេលឃាត់ខ្លួន ជនសង្ស័យអាចត្រូវបានបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬដោះលែងឲ្យមានសេរីភាព អាស្រ័យលើការសម្រេចរបស់ព្រះរាជអាជ្ញា ។

ចប់ដោយបរិបូរណ៍

សូមអរគុណ!